**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលព្រៃឈើ**
**នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ**

ភ្នំពេញ ថ្ងៃទី ខែមេសា ឆ្នាំ២០១៤

**ក្រុមការងារ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV/REL)**
**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

**តាមរយៈ:** ប្រធាននាយកដ្ឋានព្រៃឈើ និង សហគមន៍ព្រៃឈើ

**កម្មវត្ថុ:** របាយការណ៍ស្តីពីលទ្ធផលអង្គប្រជុំបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV/REL) លើកទី៨។

**ជូនភ្ជាប់:** - បញ្ជីវត្តមាន..........................................................................................ចំនួន១ច្បាប់
- ពង្រាងផែនការសកម្មភាព........................................................................ចំនួន១ច្បាប់

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើយើងខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថាកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV/REL) បានរៀបចំកិច្ចប្រជុំលើកទី៨ នៅសាលប្រជុំរដ្ឋបាលព្រៃឈើជាន់ទី១ ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

**១. សមាសភាពចូលរួម**

កិច្ចប្រជុំនេះមានសមាជិកចូលរួមចំនួន ០៨នាក់ (ដូចបញ្ជីវត្តមាននៃឯកសារជូនភ្ជាប់) មកពី៖

- ស្ថាប័នរាជរដ្ឋាភិបាលៈ រដ្ឋបាលព្រៃឈើ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ជំនាញការអន្តរជាតិៈ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA)។

**២. គោលបំណងនៃអង្គប្រជុំ**

-អង្គប្រជុំមានគោលបំណងធ្វើការបន្តពិនិត្យឡើងវិញ និងកែសម្រួលលើសេចក្តីព្រាងផែនការសកម្មភាពរបស់ MRV/REL

-បន្តពិភាក្សាលើការរៀបចំ Web platform

-បញ្ហាផ្សេងៗ។

## ៣. ដំណើរការកិច្ចប្រជុំ

-អង្គប្រជុំបានបន្តធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ លើខ្លឹមសារក្នុងសេចក្តីព្រាងផែនការសកម្មភាព REL/MRV ចាប់ពី Output ៤.២ (សកម្មភាព ៤.២.៤) និងធ្វើការកំណត់លើតារាងពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗ។

-លោក Mathieu van Rijn បានបង្ហាញបេក្ខភាពអាទិភាព សម្រាប់ជ្រើសរើសយកមកគ្រប់គ្រង Web platform គឺលោក ឡាវ វេហា ដែលជាអតីតអ្នកជំនាញការ GIS នៅក្នុងគម្រោង CLUP របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជានិស្សិតទើបបញ្ចប់ថ្នាក់ឧត្តមមកពីប្រទេសអូស្ត្រាលី ជំនាញ GIS។ ទន្ទឹមនឹងនោះ លោក Shigeru ONO បានបំផុសទីតាំងពីរសម្រាប់ដាក់ Database Server គឺ៖ នាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ម្យ៉ាងវិញទៀត គួរធ្វើការពិភាក្សាគ្នាលើសិទ្ធិនៃអ្នកប្រើប្រាស់ Web platform។

## ៤. លទ្ធផលនៃអង្គប្រជុំ

-អង្គប្រជុំបានសម្រេចនូវសេចក្តីព្រាងផែនការសកម្មភាព MRV/RELនិងបានកំណត់តារាងពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗ លើចំណុចទី Output ៤.២ (ចាប់ពីសកម្មភាព ៤.២.៤ ដល់ ៤.២.៥) ដូចឯកសារជូនភ្ជាប់

-ចំពោះករណីជ្រើសរើសអ្នកគ្រប់គ្រង សិទ្ធិនៃអ្នកប្រើប្រាស់ និង កំណត់មាតិកានៃការអភិវឌ្ឍន Web platform អង្គប្រជុំសម្រេចថា គោរពជូនថ្នាក់ដឹកនាំធ្វើការផ្តល់អនុសាសន៍ និង ពិនិត្យសម្រេច។

## ៥. ទិសដៅអនុវត្តបន្ត

ក្រុមការងារនឹងរៀបចំកិច្ចប្រជុំលើក៩ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ ដើម្បីបញ្ចប់ការពិភាក្សាលើ សេចក្តីព្រាងផែនការសកម្មភាពREL/MRV ដើម្បីនឹងដាក់ជូនថ្នាក់ដឹកនាំធ្វើការពិនិត្យសម្រេចជាផ្លូវការនាបំណាច់ខែឧសភាខាងមុខ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាជ្រាបជាសេចក្តីរាយការណ៍ ដោយអនុគ្រោះតាមការគួរ ។

លេខ.....................នពស

បានឃើញ និង បញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

"សូមមេត្តាជ្រាបជាសេចក្តីរាយការណ៍ ដោយអនុគ្រោះ "

ភ្នំពេញ ថ្ងៃទី ខែមេសា ឆ្នាំ២០១៤

**ប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ**